ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**តុលាការកំពូល** តាងនាមប្រជារាស្ត្រខ្មែរ

**សំណុំរឿង ព្រហ្មទណ្ឌ** តុលាការកំពូល

**លេខ ៖ ៥៨**

**ចុះថ្ងៃទី ១៩.០៨.១៩៩៩**

**សាលដីកាលេខ៖១៧**

**ចុះថ្ងៃទី ១០.០៥.២០០០**

បានបើកសវនាការជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១០ ខែឧសភា ឆ្នាំ ២០០០ដោយមានសមាសភាពដូចទៅ៖

១ - ឯកឧត្តម... ជាប្រធាន
២ - លោក... ជាចៅក្រម
៣ - លោក... ជាចៅក្រមរបាយការណ៍
៤ - លោក... ជាចៅក្រម
៥ - លោក... ជាចៅក្រម
លោក... ជាក្រឡាបញ្ជី

តំណាងមហាអយ្យការលោក ...ជាព្រះរាជអាជ្ញា ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ ៧១ ចុះថ្ងៃទី ២៦ ខែមីនា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ ៥៨ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ ១៩៩៩ របស់តុលាការកំពូល។

ពីបទៈប៉ុនប៉ងធ្វើមនុស្សឃាត ប្រព្រឹត្តកាលពីថ្ងៃទី ១៦.១២.១៩៩៦ នៅក្រុងភ្នំពេញ បទល្មើស ដែលមានចែងតាមបញ្ញត្តិមាត្រា៣២នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

១ - ជនជាប់ចោទឈ្មោះ **ធធ** “ជាម្ចាស់បណ្ដឹងសាទុក្ខ” ភេទប្រុស អាយុ ១៨ឆ្នាំ ជាតិខ្មែរ មុខរបរសិស្ស ទីលំនៅសព្វថ្ងៃផ្ទះលេខ ៦២អឺ០ ផ្លូវលេខ ១៥៤ ក្រុងទី២៤ សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ឪពុកឈ្មោះ... ម្ដាយឈ្មោះ...នៅលីវ គេចខ្លួនទោសពីមុនគ្មាន។

- មេធាវី លោក...

២ - ជនជាប់ចោទឈ្មោះ **ធដន** “ជាម្ចាស់បណ្ដឹងសាទុក្ខ” ភេទប្រុស អាយុ ២៨ឆ្នាំ ជាតិខ្មែរ មុខរបរ សិស្ស ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ៦២អឺ០ ផ្លូវលេខ១៥៤ ក្រុមទី២៤ សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ ក្រុងភ្នំពេញឪពុកឈ្មោះ...ម្ដាយឈ្មោះ...នៅលីវ គេចខ្លួន ទោសពីមុនគ្មាន។

- មេធាវី លោក...

៣ - ជនរងគ្រោះឈ្មោះ **ហហ** “ជាចុងបណ្ដឹងសាទុក្ខ” ភេទប្រុស អាយុ ៤៩ឆ្នាំ ជាតិខ្មែរ របររកស៊ីលក់ដូរ មានទីលំនៅផ្ទះលេខ ៣១អឺ២ ផ្លូវលេខ ១១៥ សង្កាត់ផ្សារកណ្ដាលទី១ ខណ្ឌដូនពេញ ក្រុងភ្នំពេញ។

- មេធាវី គ្មាន

- តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ **ហហ** ឆ្លើយថាៈ ថ្ងៃទី ១៦.១២ ។១៩៩៦ ម៉ោង៧ព្រឹក ពេលទៅដល់តូបលក់ដូរផ្សារកណ្ដាលស្រាប់តែឈ្មោះ **ថធ** បានស្រែកជេរប្រមាថមកលើខ្លួនដោយចោទថា ខ្លួនបាននោមដាក់តូបរបស់គាត់ គឺខ្លួនពុំបានដឹងឡើយក៏មានការទាស់សំដីគ្នា ពេលនោះឈ្មោះ **ថធ** បានស្ទុះ

មកដាល់ប្រពន្ធខ្លួនឈ្មោះ **លស** បណ្តាលឱ្យជាំភ្នែកស្តាំ ខ្លួនពុំតបវិញឡើយ ប្រធានផ្សារក៏ឃាត់ទៅ។ លុះម៉ោង ៩.៣០នាទីយប់ថ្ងៃដដែលស្រាប់តែឈ្មោះ **ធធ** និងឈ្មោះ **ធជន** បានចូលទៅលួចវាយសម្លាប់រូបខ្លួននៅតាមផ្លូវ ឌឿងហែម គឺអ្នកទាំងពីរពួនចាំសម្លាប់ជាស្រេច។ ពេលខ្លួនជិះម៉ូតូចូលទៅបានប្រហែលពីរម៉ែត្រពីជញ្ជាំង ឃើញឈ្មោះ **ធធ** កាន់បំពង់ទីប វាយសំដៅក្បាលរបស់គាត់របស់ខ្លួនបណ្តាលឱ្យបែកក្បាលចេញឈាមយ៉ាងច្រើន គឺដេរចំនួន៥ថ្នេរ។ ឈ្មោះ **ធជន** ជាអ្នកចាប់ខ្លួនជាប់ ឱ្យឈ្មោះ **ធធ** ជាអ្នកវាយសំដៅក្បាលរបស់ថែមទៀត រហូតខ្លួនសន្លប់បាត់ស្មារតី ពេលនោះមានគេស្រែកឆោឡោឡើងទើបឈ្មោះ **ធធ** និង **ធជន** រត់ឡើងម៉ូតូទៅបាត់ទៅ។ ខ្លួនសម្រាកពេទ្យរយៈពេល ១៤ថ្ងៃ។ ក្នុងរឿងនេះខ្លួនសុំឱ្យផ្តន្ទាទោសជនល្មើស និងសុំទាមទារជំងឺចិត្ត ៤.០០០ដុល្លាអាមេរិក។

-បានឃើញសេចក្តីសន្និដ្ឋាន របស់តំណាងអយ្យការអមតុលាការក្រុងភ្នំពេញ បានសម្រេចចោទប្រកាន់លើឈ្មោះ **ធជន** ភេទប្រុស អាយុ ២៨ឆ្នាំ ឈ្មោះ **ធធ** ភេទប្រុស អាយុ១៨ឆ្នាំ ពីបទប៉ុនប៉ងធ្វើឃាត ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៦.១២.៩៦ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ១៥៥ “ក” ចុះថ្ងៃទី ០៨.១២.១៩៩៧ របស់តុលាការក្រុងភ្នំពេញដែលបានសម្រេច៖

១ - ក ៖ ផ្តន្ទាទោសឈ្មោះ **ធធ** ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរដាក់ពន្ធនាគារកំណត់ចំនួន០៣ឆ្នាំ តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគារចំនួន១៥

ថ្ងៃគិតចាប់ពីថ្ងៃ ២៤.១១.៩៧ ទោសសល់ពីនេះត្រូវព្យួរទាំងអស់ដោយទុករយៈពេលសាកល្បងចំនួន០៥ឆ្នាំ។

ខ៖ ផ្តន្ទាទោសឈ្មោះ **ធដន** ភេទប្រុស អាយុ ២៨ឆ្នាំ ជាតិខ្មែរដាក់ពន្ធនាគារកំណត់ចំនួន០១ឆ្នាំតែទោសនេះ ត្រូវព្យួរទាំងអស់ ដោយទុករយៈពេលសាកល្បងចំនួន០៥ឆ្នាំ ពីបទប៉ុនប៉ងធ្វើឃាតដល់ជនរងគ្រោះឈ្មោះ **ហហ** ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៦.១២.១៩៩៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣២.៦៨និង៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

២ - បង្គាប់ឱ្យឈ្មោះ **ធដន** និង**ធធ** រួមគ្នាសងថ្លៃព្យាបាលនិងជំងឺចិត្តចំនួន ៣.០០០ ដុល្លាដល់ជនរងគ្រោះឈ្មោះ **ហហ**។ សំណូមពរលើសពីនេះបដិសេធចោល។ ក្នុងករណីទណ្ឌិត **ធដន** និង **ធធ** មិនព្រមសងធនទណ្ឌខាងលើត្រូវចាប់ដាក់គុកបង្ខំរូបកាយទារធនទណ្ឌម្នាក់ៗ២ឆ្នាំ តាមមាត្រា៧ នៃច្បាប់ស្តីពីការដាក់គុកបង្ខំលើរូបកាយក្នុងរឿងព្រហ្មទណ្ឌ។

៣ - សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ ជនរងគ្រោះសម្រេចបើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ៩៤ "ក" ចុះថ្ងៃទី ១៧.១២.៩៧ របស់ឈ្មោះ **ថធ, ធធ, ធដន និង ធធ** ដែលប្តឹងតវ៉ាពីសាលក្រមព្រហ្មទណ្ឌលេខ ១៥៥ "ក" ចុះថ្ងៃទី ០៨.១២.១៩៩៧ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចទី៣នៃសាលក្រម។

- បានឃើញសេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា៖

១- ទទួលបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ **ធធ** និងឈ្មោះ **ធជន** ចុះថ្ងៃទី១៧.១២.១៩៩៧ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែត្រូវបដិសេធចោល ដោយផ្ទុយនឹងគតិច្បាប់។

២- តម្កល់ចំណុចទី៣នៃសាលក្រមព្រហ្មទណ្ឌលេខ ១៥៥ "ក" ចុះថ្ងៃទី ០៨.១២.១៩៩៧ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល។

៣- សាលដីកានេះ ជំនុំជម្រះនិងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទទាំងពីរនាក់និង ដើមបណ្តឹងរដ្ឋប្បវេណី សម្រេចបើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់។

- បានឃើញបណ្តឹងសាទុក្ខលេខ ៣៩ ចុះថ្ងៃទី ០៦.០៥.១៩៩៩ របស់ឈ្មោះ **ថធ, ធជន និង ធធ** ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ៧១ ចុះថ្ងៃទី ២២.០៣.១៩៩៩ របស់សាលាឧទ្ធរណ៍ដែលលើកសេចក្តីសម្រេចទាំងមូល។

- បានឃើញសារណាចុះថ្ងៃទី ០៧។០៩.១៩៩៩ របស់ឈ្មោះ **ធធនិង ធជន** ជាម្ចាស់បណ្តឹងសាទុក្ខ ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់។

- បានឃើញសារណាចុះថ្ងៃទី ០៤.១០.១៩៩៩ របស់ឈ្មោះ **ហហ** ចុងបណ្តឹងសាទុក្ខ ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់។

- បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមតុលាការកំពូលថា រឿងនេះតុលាការថ្នាក់ក្រោមសម្រេចចោទប្រកាន់ជនល្មើសពីបទប៉ុនប៉ងធ្វើមនុស្សឃាត ប៉ុន្តែការសម្រេចដាក់ទណ្ឌកម្មវាផ្ទុយពីការចោទប្រកាន់ក្នុងរឿងឧក្រិដ្ឋ ធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរទៅនឹងគតិច្បាប់។ យល់ឃើញថាអំពើល្មើស

នេះពុំមានលក្ខណៈជាបទល្មើសប៉ុនប៉ងធ្វើមនុស្សឃាតឡើយគឺជាបទល្មើសបង្ក របួសស្នាមតែប៉ុណ្ណោះ។ មហាអយ្យការការអមតុលាការកំពូល សូមធ្វើសេចក្តីសន្និដ្ឋានជូនក្រុមប្រឹក្សាជំនុំជម្រះដូចតទៅ៖

១- បណ្តឹងសាទុក្ខរបស់ឈ្មោះ **ថធ, ធជន និង ធធ** ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់។

២-បដិសេធសាលដីកាព្រហ្មទណ្ឌលេខ៧១ចុះថ្ងៃទី ២៦.០៣.១៩៩៩ របស់សាលាឧទ្ធរណ៍ទុក្ខជាអសារឥតការ។

- បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះ **ធធ** ជាម្ចាស់បណ្តឹងសាទុក្ខនៅពេលជំនុំជម្រះថាៈ បានជាខ្ញុំប្តឹងសាទុក្ខព្រោះឈ្មោះ **ហហ** ទាមទារសំណងច្រើនពេក ម្យ៉ាងទៀតក្នុងរឿងនេះ គាត់ក៏បានវាយបំផ្លាញសម្ភារលក់ដូររបស់ម្តាយខ្ញុំខូចខាតអស់ច្រើនដែរ ហេតុនេះសូមតុលាការពិនិត្យពិចារណា។

- បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះ **ធជន** ជាម្ចាស់សាទុក្ខនៅពេលជំនុំជម្រះថាៈក្នុងរឿងនេះឈ្មោះ **ហហ** ជាអ្នកផ្តើមជម្លោះមុខគាត់បានធ្វើឱ្យខូចខាតសម្ភារលក់ដូររបស់ម្តាយខ្ញុំមួយចំនួនដែរ ខ្ញុំគ្មានចេតនាវាយគាត់ទេ សូមតុលាការមេត្តាពិនិត្យពិចារណា។

-បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះ **ធថ** ជាម្ចាស់បណ្តឹងសាទុក្ខនៅពេលជំនុំជម្រះថាៈ ខ្ញុំបាទក៏យល់ឃើញដូចកូនដែរ ហេតុនេះសូមតុលាការពិចារណាអំពីសំណងផង។

-បានស្តាប់ចម្លើយដោះសារបស់ឈ្មោះ **ហហ** ជាចុងចោទបណ្តឹងសាទុក្ខនៅពេលជំនុំជម្រះថា៖ ចំពោះចម្លើយរបស់ជនជាប់ចោទ គឺជាការឆ្លើយដោះសារ ជនជាប់ចោទបានទៅរងចាំវាយខ្ញុំជាមុន។ រឿងដំបូងគឺឈ្មោះ **ថធ** បានចោទ

ខ្ញុំបាទថានោមដាក់តូបគាត់ ហើយក៏ឈ្លោះពាក្យសំដីគ្នានៅក្នុងផ្សារ ឈ្មោះ **ថធ** បានវាយប្រពន្ធខ្ញុំបាទ ហើយបានអ្នកជិតខាងនិងសន្តិសុខផ្សារមកឃាត់ ហើយបែកគ្នារៀងខ្លួនទៅ។

-មេធាវីការពារជនជាប់ចោទបានសន្និដ្ឋានថាៈ ក្នុងរឿងនេះដំបូងគឺវាយគ្នាទៅវិញទៅមក ហើយមានរបួសរៀងៗខ្លួន។ ឯជនជាប់ចោទពេលត្រឡប់មកពីរៀនក៏ទៅផ្សារហើយបានដំណឹងថាម្តាយឪពុកខ្លួនឈ្លោះគ្នាជាមួយឈ្មោះ **ហហ** ហើយត្រូវទទួលរងរបួស បានទៅមន្ទីរពេទ្យអស់ហើយ ក្រោយមកជនជាប់ចោទ បានទៅសួរនាំឈ្មោះ **ហហ** អំពីរឿងហេតុនេះ។ ជនជាប់ចោទពុំមានបំណងទៅវាយសម្លាប់ជនរងគ្រោះទេ។ ម៉្យាងទៀតការសម្រេចរបស់តុលាការថ្នាក់ក្រោមអំពីសំណងនោះគឺវាមានកំរិតខ្ពស់ណាស់ កូនក្តីខ្ញុំគ្មានលទ្ធភាពសងទេ សូមតុលាការពិចារណា។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៩ចុះថ្ងៃទី ០៦.០៥.១៩៩៩ របស់ឈ្មោះ **ថធ, ធជន និង ធធ** ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះ មកជំនុំជម្រះបាន តាមមាត្រា១៤នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី។

-យល់ឃើញថាមានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ **ធធ និង ធជន** ពីបទប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនាមានអាវុធ ប្រព្រឹត្តនៅក្រុងភ្នំពេញកាលពីថ្ងៃទី ១៦.១២.៩៦ ប្រាកដមែន ហើយត្រូវបានតុលាការក្រុងភ្នំពេញ សម្រេចផ្តន្ទាទោសជនជាប់ចោទទាំងពីរនាក់ ក្រោមអប្បបរិមានៃទោស ព្រមទាំងព្យួរទោសដោយអនុវត្តក្នុងពន្ធនាគារតែ១៥ថ្ងៃ។ ប៉ុន្តែសាលក្រមនេះពុំត្រូវបានព្រះរាជអាជ្ញាប្តឹងឧទ្ធរណ៍ទេ។ ដូច្នេះសាលាឧទ្ធរណ៍ ក៏ដូចជាតុលាការកំពូលដែរពុំមានសមត្ថកិច្ចទុកជាមោឃៈបានឡើយ។

-យល់ឃើញថា ការដែលជនជាប់ចោទនិងមេធាវីជនជាប់ចោទលើកឡើងនាពេលសវនាការនេះថា ជនជាប់ចោទ ពុំមានចេតនាប៉ុនប៉ងធ្វើមនុស្សឃាតទេ គ្រាន់តែទៅសួរនាំរកខុសត្រូវ នោះជាការពុំត្រឹមត្រូវទេ ពីព្រោះអង្គហេតុនៃរឿងនេះបញ្ជាក់ឱ្យឃើញថា ជនជាប់ចោទពិតជាបានកាន់បំពង់ទីបទៅពួនស្ទាក់ចាំវាយឈ្មោះ **ហហ** ប្រាកដមែន។

-យល់ឃើញថា ការដែលជនជាប់ចោទ និងមេធាវីជនជាប់ចោទ លើកឡើងនាពេលសវនាការនេះ ថាតុលាការឱ្យសង ៣.០០០ដុល្លារអាមេរិកជាការធ្ងន់ធ្ងរពេកណាស់នោះ តុលាការកំពូល ពុំមានសមត្ថកិច្ចពិចារណាបានឡើយ ពីព្រោះ តុលាការកំពូលជំនុំជម្រះពេលនេះលើអង្គច្បាប់ប៉ុណ្ណោះ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៧១ចុះថ្ងៃទី ២៦.០៣.១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះមានការខុសឆ្គងអំពីការផ្តន្ទាទោសក្រោមអប្បបរិមានៃទោសនិងអនុវត្តទោសព្យួរ ប៉ុន្តែតុលាការកំពូល ពុំមានសមត្ថកិច្ចទុកជាមោឃៈបានទេ ព្រោះគ្មានបណ្តឹងនិងសាទុក្ខពីដើមបណ្តឹងរដ្ឋប្បវេណី តំណាងអយ្យការ។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខជនជាប់ចោទនិងដើមបណ្តឹងរដ្ឋប្បវេណី

១-ទទួលបណ្តឹងសាទុក្ខលេខ ៣៩ ចុះថ្ងៃទី ០៦.០៥.១៩៩៩ របស់ឈ្មោះ **ថធ, ធជន និង ធធ** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៧១ ចុះថ្ងៃទី ២៦.០៣.១៩៩៩ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល។

៣-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០០។